## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសដ៏នក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរ ថ្វាយ **ព្រះករុណា-ជាអម្ចាស់ជីវិតលើត្បូង** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅប្រជារាស្ត្រ ទាំងក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវកត្តញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាធិគុណរបស់ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ដែលជានិច្ចកាលព្រះអង្គតែងបានបំពេញព្រះរាជកិច្ចដោយមិនខ្លាចនឿយហត់ព្រះកាយពល និងព្រះបញ្ញាញាណ ក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ។ ព្រមជាមួយនេះព្រះអង្គបានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យផ្ទាល់ របស់ព្រះអង្គយ៉ាងច្រើនសន្ធឹកសន្ធាប់ជួយដល់ប្រជារាស្ត្រទូទៅ និងតែងបានយកព្រះរាជហឫទ័យទុកដាក់ជាទីបំផុតរាល់ព្រះរាជកិច្ចនិងសង្គមកិច្ច នាំមកនូវភាពសុខដុមរមនាជូនប្រជារាស្ត្រខ្មែរទូទាំងប្រទេស។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏មហាជ័យមង្គលនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតាឆ្នាំថ្មី ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ប្រោសព្រះរាជទានប្រសិទ្ធិពរជ័យ ថ្វាយ **ព្រះករុណា-ជាអម្ចាស់ជីវិតលើត្បូង** ប្រកបដោយព្រះបរមសុខ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ព្រមទាំងប្រជារាស្ត្រខ្មែរអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃអង្គារ ៥កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**